**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៧៦ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការកែសម្រួលក្រុមប្រឹក្សាកំណែទម្រង់កងយោធពលខេមរភូមិន្ទ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០២/នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសម្រួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០០/២៨៤ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៧១ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៩ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់កងយោធពលខេមរភូមិន្ទ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១.-** ត្រូវបានកែសម្រួលក្រុមប្រឹក្សាកំណែទម្រង់កងយោធពលខេមរភូមិន្ទ ដែលមានសមាសភាពដូចខាងក្រោម៖

១-នាយឧត្តមសេនីយ៍ **ទៀ បាញ់** អត្តលេខ ០០០០០៦ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ ជាប្រធាន

២-នាយឧត្តមសេនីយ៍ **ប៉ុល សារឿន** អត្តលេខ ០០០០១៧ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ ជាអនុប្រធាន

៣-នាយឧត្តមសេនីយ៍ **ចាយ សាំងយុន** អត្តលេខ ០០០០១០ រដ្ឋលេខាធិការ ក.ព.ជ ជាអនុប្រធាន

៤-នាយឧត្តមសេនីយ៍ **គន់ គីម** អត្តលេខ ០០៤៤៥៦ អគ្គមេបញ្ជាការរង និងជានាយសេនាធិការចម្រុះ ជាអនុប្រធាន

៥-នាយឧត្តមសេនីយ៍ **នាង ផាត** អត្តលេខ ០០០០៨០ រដ្ឋលេខាធិការ ក.ព.ជ ជាសមាជិក

៦-នាយឧត្តមសេនីយ៍ **ម៉ឹង សំផន** អត្តលេខ ០០០០៧១ រដ្ឋលេខាធិការ ក.ព.ជ ជាសមាជិក

៧-នាយឧត្តមសេនីយ៍ **ឯល វណ្ណសារ៉ាត** អត្តលេខ ០០០០៥៤ រដ្ឋលេខាធិការ ក.ព.ជ ជាសមាជិក

៨-លោកជំទាវ **ឌាំ ដារីនី** រដ្ឋលេខាធិការ ក.ព.ជ ជាសមាជិក

៩-នាយឧត្តមសេនីយ៍ **ត្អូង ស៊ីផាន** អត្តលេខ ០០០០៥១ អនុរដ្ឋលេខាធិការ ក្រសួងការពារជាតិ ជាសមាជិក

១០-នាយឧត្តមសេនីយ៍ **មាស សុភា** អត្តលេខ ០០០០១៦ អគ្គមេបញ្ជាការរង និងជាមេបញ្ជាការ ក.ជ.គ ជាសមាជិក

១១-នាយឧត្តមសេនីយ៍ **ហ៊ីង ប៊ុនហៀង** អត្តលេខ ០០០៤៤៤ អគ្គមេបញ្ជាការរង, នាយករងខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងជាមេបញ្ជាការ បញ្ជាការដ្ឋានអង្គរក្ស ជាសមាជិក

១២-នាយឧត្តមសេនីយ៍ **ជា តារា** អត្តលេខ ០០០១៨៣ អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ ជាសមាជិក

១៣-នាយឧត្តមសេនីយ៍ **គឹម ប៊ុនថាន** អត្តលេខ ០០៤៣៥៧ អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ ជាសមាជិក

១៤-នាយឧត្តមសេនីយ៍ **សៅ សុខា** អត្តលេខ ០០០១០៥ អគ្គមេបញ្ជាការរង និងជាមេបញ្ជាការ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស ជាសមាជិក

១៥-នាយឧត្តមសេនីយ៍ **ញឹក ឈួន** អត្តលេខ ០០០០៥០ អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ ជាសមាជិក

១៦-នាយឧត្តមសេនីយ៍ **អ៊ុំ សំខាន់** អត្តលេខ ០០០០៤២ អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ ជាសមាជិក

១៧-នាយឧត្តមសេនីយ៍ **ម៉ក់ សារុន** អត្តលេខ ០០០០៩១ អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ ជាសមាជិក

១៨-នាយឧត្តមសេនីយ៍ **ឥត សារ៉ាត់** អត្តលេខ ០០០៣៣៤ អគ្គមេបញ្ជាការរងនិង ជានាយកទីចាត់ការហ្វឹកហ្វឺន ជាសមាជិក

១៩-នាយឧត្តមសេនីយ៍ **សំ វណ្ណថន** អត្តលេខ ០០០២០៥ អគ្គលេខាធិការ ក្រសួងការពារជាតិ ជាសមាជិក

២០-នាយឧត្តមសេនីយ៍ **ទៅ តិរុណា** អត្តលេខ ០០០០៧៥ អគ្គនាយក អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស ជាសមាជិក

២១-នាយឧត្តមសេនីយ៍ **ស៊ុំ សំណាង** អត្តលេខ ០០០០៧៤ អគ្គនាយក អគ្គនាយកដ្ឋានកស្តុការ ហិរញ្ញវត្ថុ ជាសមាជិក

២២-នាយឧត្តមសេនីយ៍ **មាស សាម៉ន** អត្តលេខ ០០០០៧៩ អគ្គនាយក អគ្គនាយកដ្ឋានយោធសេវា ជាសមាជិក

២៣-នាយឧត្តមសេនីយ៍ **ណឹម សុខគិ្ត** អត្តលេខ ០០០០៦៩ អគ្គនាយក អគ្គន.ដ្ឋាននយោបាយ និងកិច្ចការបរទេស ជាសមាជិក

២៤-នាយឧត្តមសេនីយ៍ **សឹង សំណាង** អត្តលេខ ០០០១០១ មេបញ្ជាការ បញ្ជាការ-ដ្ឋានកងទ័ពជើងអាកាស ជាសមាជិក

២៥-នាយឧត្តមនាវី **ទៀ វិញ** អត្តលេខ ០០០១០៧ មេបញ្ជាការ បញ្ជាការ-ដ្ឋានកងទ័ពជើងទឹក ជាសមាជិក

២៦-នាយឧត្តមសេនីយ៍ **មាស សំអុល** អត្តលេខ ០០០២១១ អគ្គនាយករង និងជានាយក នាយកដ្ឋានបុគ្គលិក ជាសមាជិក

២៧-ឧត្តមសេនីយ៍ឯក **ជឹម សុខ** អត្តលេខ ០០០៦៤៦ នាយរងសេនាធិការចម្រុះ និងជានាយកទីចាត់កាបុគ្គលិក ជាសមាជិក

២៨-ឧត្តមសេនីយ៍ឯក **ជា សារ៉ែន** អត្តលេខ ០០០០៩០ មេបញ្ជាការរង និងជានាយសេនាធិការ ក.ជ.គ ជាសមាជិក

២៩-ឧត្តមសេនីយ៍ឯក **ហ៊ុន ម៉ាណែត** អត្តលេខ ០៣៣៨៨៣ មេបញ្ជាការរង ក.ជ.គ និងជាមេបញ្ជាការ បញ្ជាការដ្ឋានកម្លាំងពិសេសប្រឆាំងភេរវកម្ម ជាសមាជិក

**មាត្រា ២**.- ក្រុមប្រឹក្សាកំណែទម្រង់កងយោធពលខេមរភូមិន្ទ មានភារកិច្ចដូចខាងក្រោម៖

- ធ្វើផែនការកំណែទម្រង់ និងផែនការកសាងកម្លាំងយូរអង្វែង ដែលទាក់ទងទៅនឹងការងារកំណែទម្រង់កងយោធពលខេមរភូមិន្ទ តាមទិសដៅរបស់ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ។
- តាមដានត្រួតពិនិត្យជាអចិន្ត្រៃយ៍នូវកម្មវិធីកំណែទម្រង់។
- សរុបលទ្ធផលការងារកំណែទម្រង់កងយោធពលខេមរភូមិន្ទជូនឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ។
- ក្រុមប្រឹក្សាកំណែទម្រង់កងយោធពលខេមរភូមិន្ទ មានសិទ្ធិបង្កើតគណៈកម្មការជំនាញទៅតាមសភាពការណ៍ចាំបាច់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ។

**មាត្រា៣.-** ត្រូវបានកែសម្រួលអគ្គលេខាធិការដ្ឋានទទួលបន្ទុកការងារអចិន្ត្រៃយ៍ដែលមានសមាសភាពដូចខាងក្រោម៖

១-នាយឧត្តមសេនីយ៍ **ទួន ស៊ីផាន** អត្តលេខ ០០០០៥១ អនុរដ្ឋលេខាធិការក្រសួងការពារជាតិ ជាអគ្គលេខាធិការ

២-នាយឧត្តមសេនីយ៍ **មាស សំអុល** អត្តលេខ ០០០២១១ អគ្គនាយករង អគ្គនាយកដ្ឋានយោធសេវា និងជានាយក នាយកដ្ឋានបុគ្គលិក ជាអគ្គលេខាធិការរង

៣-ឧត្តមសេនីយ៍ឯក **លី ដេត** អត្តលេខ ០០០០២៩ អគ្គនាយករង អគ្គ-នាយកដ្ឋានភស្តុភារហិរញ្ញវត្ថុ ជាអគ្គលេខាធិការរង

៤-ឧត្តមសេនីយ៍ឯក **ផន ណារ៉ា** អត្តលេខ ០០០០៧៨ អគ្គនាយករង អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស និងជានាយក នាយកដ្ឋានបញ្ជូនសារ ជាអគ្គលេខាធិការរង

៥-ឧត្តមសេនីយ៍ឯក **ខៅ សាខន** អត្តលេខ ០០១២០៣ អគ្គលេខាធិការរងក្រសួងការពារជាតិ ជាអគ្គលេខាធិការរង

៦-ឧត្តមសេនីយ៍ឯក **ខៀវ វាសនា** អត្តលេខ ០០០៦៨៦ នាយរងសេនាធិការចំរុះ និងជានាយកទីចាត់ការកលយុទ្ធ ជាអគ្គលេខាធិការរង

៧-ឧត្តមសេនីយ៍ឯក **ជឹម សុខ** អត្តលេខ ០០០៦៤៦ នាយរងសេនាធិការចម្រុះ និងជានាយកទីចាត់ការបុគ្គលិក ជាអគ្គលេខាធិការរង

៨-ឧត្តមសេនីយ៍ឯក **ស៊ុន គឹមសិន** អត្តលេខ ០០០៤៩៦ អគ្គនាយករង អគ្គ-នាយកដ្ឋានសម្ភារៈបច្ចេកទេស និងជានាយក នាយកដ្ឋានបំពាក់សម្ភារៈសឹក ជាអគ្គលេខាធិការរង

៩-ឧត្តមសេនីយ៍ឯក **ហ៊ុន ម៉ាណែត** អគ្គលេខ ០៣៣៨៨៣ មេបញ្ជាការរង ក.ជ.គ និងជាមេបញ្ជាការ បញ្ជាការដ្ឋានកម្លាំងពិសេសប្រឆាំងភេរវកម្ម ជាអគ្គលេខាធិការរង

១០-ឧត្តមសេនីយ៍ទោ **ជួប សំបូរ** អគ្គលេខ ០០១៤១៣ នាយករង នាយកដ្ឋានបុគ្គលិក ជាសមាជិកអចិន្ត្រៃយ៍

១១-ឧត្តមសេនីយ៍ទោ **ខ៊ាន ប៊ុន្នី** អគ្គលេខ ០០០១០៤ នាយករងទីចាត់ការហិរញ្ញវត្ថុអគ្គបញ្ជាការ ជាសមាជិក

១២-ឧត្តមសេនីយ៍ទោ **អ៊ួន លន** អគ្គលេខ ០០០២៧៧ នាយរងសេនាធិការ និងជានាយការិយាល័យទី ១ ក.ជ.គ ជាសមាជិក

១៣-ឧត្តមសេនីយ៍ទោ **ញឹម សុវណ្ណា** អគ្គលេខ ០០៣៣៩៨ នាយរងសេនាធិការ និងជានាយការិយាល័យទី ១ ក.ជ.អ ជាសមាជិក

១៤-ឧត្តមសេនីយ៍ត្រី **ឈឹម សាម៉ឺឌី** អគ្គលេខ ០១៦៧៦៤ នាយករងទីចាត់ការបុគ្គលិក អគ្គបញ្ជាការ ជាសមាជិកអចិន្ត្រៃយ៍

១៥-ឧត្តមសេនីយ៍ត្រី **ស្រ៊ុន គឹមស្រៀង** អគ្គលេខ ០០៥១៦៥ នាយរងសេនាធិការ និងជានាយការិយាល័យទី ១ អ.ហ ជាសមាជិក

១៦-វរនាវីឯក **ឡើង ខ៊ាន់ឡើន** អគ្គលេខ ០១៤៩៨៦ នាយការិយាល័យបុគ្គលិក ក.ជ.ទ ជាសមាជិក

**មាត្រា ៤.-** អគ្គលេខាធិការដ្ឋានទទួលបន្ទុកធ្វើជាសេនាធិការផ្ទាល់របស់ក្រុមប្រឹក្សាកំណែទម្រង់កងយោធពលខេមរភូមិន្ទហើយមានភារកិច្ចដូចខាងក្រោម៖

- ស្រាវជ្រាវ ពិចារណា និងលើកយោបល់ស្តីពីការកែទម្រង់ជូនក្រុមប្រឹក្សាកំណែទម្រង់កងយោធពលខេមរភូមិន្ទ។
- ពិនិត្យផែនការ និងជំរុញការងារកំណែទម្រង់កងយោធពលខេមរភូមិន្ទ។
- ណែនាំដំណើរការកម្មវិធីការងាររបស់គណៈកម្មការកំណែទម្រង់ ធានាឲ្យដំណើរការតាមផែនការកំណត់ ដោះស្រាយរាល់សំណើរបស់គណៈកម្មការដែលជួបការលំបាក។
- ធ្វើការងារមួយចំនួនទៀតដែលប្រធានក្រុមប្រឹក្សាកំណែទម្រង់កងយោធពលខេមរភូមិន្ទប្រគល់ឲ្យ។

**មាត្រា ៥.-** រាល់បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៦**.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលមានការពាក់ព័ន្ធ និងសមាសភាពក្នុងមាត្រា១ មាត្រា៣ ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែឧសភា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីសុំសេចក្តីសម្រេចដ៏ខ្ពង់ខ្ពស់

រាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែ មេសា ឆ្នាំ២០១៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ បាញ់**

**<u>កន្លែងទទួល</u>**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ទៀ បាញ់
-ដូចមាត្រា១, ៣, ៦
-ឯកសារ-កាលប្បវត្តិ